ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គិសនីកម្ពុជា
គណៈកម្មាធិការលទ្ធកម្ម
លេខៈ....1737.....PC អ.ក

# សេចក្តីជូនដំណឹងលើកទី២
## ស្តីពី
## ការងារជួសជុលបន្ទប់ការិយាល័យទំហំ(7.5m x 4.0m)នៅជាន់ទី៣ នៅស្នាក់ការកណ្តាលអគ្គិសនីកម្ពុជា ជូននាយកដ្ឋានសវនកម្មផ្ទៃក្នុង

អគ្គិសនីកម្ពុជាសូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឲ្យបានជ្រាបថាៈ អគ្គិសនីកម្ពុជានឹងដាក់ឲ្យពិគ្រោះថ្លៃជាសាធារណៈដើម្បីជ្រើសរើសអ្នកទទួលការអញ្ជើញចូលរួមពិគ្រោះថ្លៃស្តីពីការងារជួសជុលបន្ទប់ការិយាល័យទំហំ(7.5m x 4.0m)នៅជាន់ទី៣ នៅស្នាក់ការកណ្តាលអគ្គិសនីកម្ពុជា ជូននាយកដ្ឋានសវនកម្មផ្ទៃក្នុង។

អគ្គិសនីកម្ពុជាបានរៀបចំឯកសារសំរាប់ក្រុមហ៊ុន/សហគ្រាសបំពេញដើម្បីចូលរួមពិគ្រោះថ្លៃ។ ឯកសារពិគ្រោះថ្លៃមាន ដាក់លក់នៅអង្គភាពលទ្ធកម្មដែលមានអាស័យដ្ឋានៈ ផ្លូវព្រះយុគន្ធរ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ ចាប់ពីថ្ងៃទី ១៤ ខែ សីហា ឆ្នាំ២០១៧ តទៅរៀងរាល់ម៉ោងធ្វើការ (ទូរស័ព្ទទាក់ទងៈ 023 67 66 007 និង Website: www.edc.com.kh) ។

ឯកសារពិគ្រោះថ្លៃដែលបានបំពេញរួចត្រូវប្រគល់ជូនអង្គភាពលទ្ធកម្ម យ៉ាងយូរបំផុតត្រឹម ថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១៧ វេលាម៉ោង ១១ : 00 នាទី ។

ការបើកសំណើពិគ្រោះថ្លៃនឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្ម តាមអាស័យដ្ឋានខាងលើ វេលាម៉ោង ១៥:៤៥ នាទី ថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១៧ ។

ក្រុមហ៊ុន/សហគ្រាស ដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬ មានប្រគពតែមួយអាចដាក់សំណើពិគ្រោះថ្លៃបានតែមួយគត់។

ក្រុមហ៊ុន/សហគ្រាស ដែលមានបំណងចូលរួមពិគ្រោះថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្ម ដើម្បីទិញឯកសារពិគ្រោះថ្លៃ និងសាកសួរព័តមានដែលទាក់ទងនឹងការដេញថ្លៃនេះ។

រាជធានីភ្នំពេញ, ថ្ងៃទី 14 ខែ ០៨ ឆ្នាំ ២០១៧
**ប្រធានគណៈកម្មាធិការលទ្ធកម្ម**

ឆឹង_អ៊ីង

ចម្លងជូនៈ
-អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
-អង្គភាពប្រឆាំងអំពើពុករលួយ